**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ក្រុមប្រឹក្សាជាតិគណនេយ្យ**
លេខ ០០៧ ក.ជ.គ

ថ្ងៃព្រហស្បតិ៍ ១រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យអនុវត្តសាកល្បងនៃកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម, អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និង ប្រកាសលេខ ៥៦៣ សហវ.ប្រក ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ក្រុមប្រឹក្សាជាតិគណនេយ្យសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ក្រុមប្រឹក្សាជាតិគណនេយ្យបានសម្រេចដាក់ឱ្យអនុវត្តសាកល្បងនូវកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ នឹងចាប់ផ្តើមអនុវត្តកម្មវិធីនេះដោយធ្វើការជ្រើសរើសរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសយ៉ាងតិចចំនួន១០ សម្រាប់ការិយបរិច្ឆេទគណនេយ្យមុនឆ្នាំ២០២០ ដែលសហគ្រាសបានបញ្ជូនមកក្រុមប្រឹក្សាជាតិគណនេយ្យ។

គោលបំណងនៃការដាក់ឱ្យអនុវត្តកម្មវិធីនេះ គឺដើម្បីត្រួតពិនិត្យពីកម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ធៀបនឹងលក្ខខណ្ឌតម្រូវចាំបាច់នានាដែលច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធបានកំណត់។ ក្នុងដំណាក់កាលសាកល្បងនេះ, ក្រុមប្រឹក្សាជាតិគណនេយ្យនឹងមិនអនុវត្តទោសទណ្ឌឡើយលើសហគ្រាសណាមួយដែលលទ្ធផលនៃការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុបង្ហាញថាមិនបានអនុលោម ឬបានអនុលោមតិចតួចតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅឡើយទេ ។

ក្រោយការអនុវត្តសាកល្បង, កម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសនឹងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់តាមការចាំបាច់។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាស និងសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន។

**ក្រុមប្រឹក្សាជាតិគណនេយ្យ**